ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# មិនមានករណីព្យាបាលជាសះស្បើយ
# និងមិនមានករណីវិជ្ជមានកូវីដ-១៩ ថ្មី នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ ១៩ នៅទូទាំងប្រទេស ៖**

ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

– អ្នកព្យាបាលជាសះស្បើយ សរុបមានចំនួនកើនឡើងដល់ ១២១នាក់ (ស្មើនឹង ៩៩,១៨% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់ នៅក្នុងចំនួននេះ មានស្រី ៣៧នាក់ និងបុរស ៨៣នាក់) ដែលមានបុរសជនជាតិចិន ០១នាក់ ស្ត្រីជនជាតិចិន ០២នាក់ ស្ត្រីជនជាតិអង់គ្លេស ០៣នាក់ បុរសជនជាតិអង់គ្លេស ០២នាក់ បុរសជនជាតិអាមេរិកកាំង ០១នាក់ ស្ត្រីជនជាតិអាមេរិកកាំង ០១នាក់ បុរសជនជាតិបែលហ្ស៊ិក ០១នាក់ បុរសជនជាតិបារាំង ១៩នាក់ (ក្នុងនេះ មានទារកអាយុ ០៤ខែ) ស្ត្រីជនជាតិបារាំង ២១នាក់ បុរសជនជាតិកាណាដា ០២នាក់ បុរសជនជាតិម៉ាឡេស៊ី ១៣នាក់ បុរសជនជាតិឥណ្ឌូនេស៊ី ០២នាក់ ស្ត្រីជនជាតិវៀតណាម ០៣នាក់ បុរសជនជាតិខ្មែរ ៤៣នាក់ និងស្ត្រីជនជាតិខ្មែរ ០៧នាក់ (គិតចាប់ពីខែមករាដល់បច្ចុប្បន្ននេះ)។

– អ្នកដែលកំពុងសម្រាកព្យាបាលសរុបបានថយចុះមកនៅចំនួន ០១នាក់ (ស្ត្រី ០១នាក់នៅខេត្តបន្ទាយមានជ័យ) ដែលឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានសម្រេចបញ្ជូនមកបន្តការព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ នាថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០។

– អ្នកមានវីរុសកូវីដ-១៩ ដែលបានរកឃើញទាំងអស់ (រាប់ទាំងអ្នកដែលបានព្យាបាលជាសះស្បើយ និងអ្នកដែលកំពុងព្យាបាល) នៅទូទាំងប្រទេសសរុបចំនួន ១២២នាក់ (ស្ត្រី ៣៨នាក់ និងបុរស ៨៤នាក់)។

**២. មិនមានករណីជាសះស្បើយ និងមិនមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ឡើយ** នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០។

**៣. ចំនួនសរុបវត្ថុសំណាកដែលបានធ្វើវិភាគ** ទាំងអស់មានចំនួន ១៤,៦១៥ សំណាក សម្រាប់ទូទាំងប្រទេស (គិតចាប់តាំងពីខែមករា ឆ្នាំ២០២០ មកដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០) ដែលក្នុងចំណោមនេះ ប្រជាជន



ទីស្តីការក្រសួងសុខាភិបាល ផ្ទះលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ... ៥០៩

និងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក និង វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

មួយលាននាក់ កម្ពុជាបានធ្វើវិភាគបានចំនួន ៨៩៩សំណាក ដែលជាចំនួនច្រើនជាងបណ្តាប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ានយើងនេះ។

សូមរំលឹកសារជាថ្មីម្តងទៀតថា ដើម្បីបន្តរក្សានូវកិច្ចការពារកុំឲ្យមានរលកទីពីរនៃការចម្លងវីរុសកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានធ្វើការក្រើនរំលឹក និងបន្តអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឲ្យចូលរួមអនុវត្តន៍វិធានការការពារខ្លួន បើទោះបីជាប្រទេសកម្ពុជា មិនមានរកឃើញករណីជំងឺកូវីដ-១៩ ថ្មី ក្នុងរយៈពេលជាងមួយខែកន្លងមកនេះក្តី ក៏ប៉ុន្តែបុគ្គលគ្រប់រូបត្រូវមានការប្រុងប្រយ័ត្ន និងអនុវត្តវិធានការការពារការចម្លងឲ្យបានជាប់ជានិច្ច ដោយត្រូវចេះកែប្រែទម្លាប់ និងឥរិយាបទនៃការរស់នៅរបស់ខ្លួនឲ្យស្របទៅតាម "*សភាពធម្មតាតាមបែបគន្លងថ្មី (New Normal Life) ក្នុងបរិបទប្រយុទ្ធនឹងជំងឺកូវីដ-១៩*" ជាចាំបាច់ ដូចជាការប្រកាន់យកនូវការអនុវត្តអនាម័យដៃស្អាត ពាក់ម៉ាស់ (ក្នុងករណីចាំបាច់) ប្រើក្រម៉ា កន្សែង ឬក្រដាសជូតមាត់ ខ្ទប់មាត់ពេលមានក្អកកណ្តាស់ បន្តអនុវត្តន៍គម្លាតសុវត្ថិភាពសង្គម និងគម្លាតសុវត្ថិភាពបុគ្គល មិនត្រូវមានការជួបជុំ ឬរៀបចំពិធីណាមួយដែលមានគ្នាច្រើនកុះករពេក ដូចជាការជួបជុំស៊ីផឹកដែលមានគ្នាច្រើន ឬការជួបជុំតាមបែបសាសនា ជាដើម ។ ម្ចាស់ភោជនីយដ្ឋាន និងអាហារដ្ឋាន ព្រមទាំងកន្លែងលក់ដូរផ្សេងៗ ត្រូវតែបន្តអនុវត្តន៍វិធានការការពារឲ្យទៅតាមបែបនៃការរស់ "*សភាពធម្មតាតាមបែបគន្លងថ្មី ក្នុងបរិបទប្រយុទ្ធនឹងជំងឺកូវីដ-១៩*" នៅកម្ពុជា ដូចបានជម្រាបជូនខាងលើនេះស្រាប់ ប្រកបដោយការទទួលខុសត្រូវខ្ពស់ និងត្រូវធានាថា ទីតាំងធុរកិច្ចរបស់ខ្លួនមិនត្រូវក្លាយជាទីកន្លែងចម្លងវីរុសកូវីដ-១៩ ដល់អតិថិជន ឬអ្នកបម្រើការនៅទីនោះឡើយ។

លើសពីនេះ ឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល ក៏បានធ្វើការណែនាំដល់មន្ទីរសុខាភិបាលរាជធានី-ខេត្តទាំងអស់ ព្រមទាំងបុគ្គលិក មន្ត្រីសុខាភិបាល ជាពិសេសក្រុមគ្រូពេទ្យនៅគ្រប់លំដាប់ថ្នាក់ (ទាំងថ្នាក់ជាតិ និងក្រោមជាតិ) ឲ្យយកចិត្តទុកដាក់ បន្តការផ្តល់ការថែទាំ និងព្យាបាលអ្នកជំងឺផ្សេងៗទៀត ទន្ទឹមគ្នាទៅនឹងការយកចិត្តទុកដាក់ផ្តល់សេវាពិនិត្យព្យាបាលអ្នកជំងឺកូវីដ-១៩ ហើយត្រូវបង្កើនការយកចិត្តទុកដាក់ និងបន្តការងារផ្តល់សេវាសុខាភិបាលនានា ដូចជាសកម្មភាពផ្តល់សេវាសុខភាពមាតា កុមារ និងទារក ការងារចាក់ថ្នាំបង្ការ កិច្ចការពារជំងឺគ្រុនឈាម ការងារប្រយុទ្ធប្រឆាំងទៅនឹងជំងឺគ្រុនចាញ់ អេដស៍ និងរបេង ដែលកម្មវិធីគ្រុនចាញ់នេះទាមទារនូវការខិតខំរួមគ្នាថែមទៀតដើម្បីឆ្ពោះទៅរកការលុបបំបាត់ជំងឺនេះទាំងស្រុង ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញឲ្យអនុវត្តន៍ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា** ដោយមិនត្រូវឲ្យមានការអាក់ខាន ឬរាំងស្ទះដំណើរការផ្តល់សេវាសុខាភិបាលណាមួយ ដោយសារតែជំងឺកូវីដ-១៩ នេះឡើយ។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ